នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Feb-2012, 08:27
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើសុំឲ្យមានការដាក់បង្ហាញឯកសារពីសម័យនោះជាសំណៅដើម នៅក្នុងសវនាការ" របស់ ខៀវ សំផន**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន
មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១២ មេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់ *សំណើសុំឱ្យមានការដាក់ឯកសារពីសម័យនោះ ជាសំណៅដើម នៅក្នុងសវនាការ* ("សំណើ")[1]។ដំណោះស្រាយជាចំបងដែលបានស្វែងរកតាមរយៈសំណើនេះ គឺដីកាសម្រេចមួយពីអង្គជំនុំជម្រះសាលាដំបូង ឱ្យបង្គាប់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") ពាក់ព័ន្ធនឹងឯកសារ ទាំងអស់ដែលមាននៅក្នុងសំណុំរឿងដែលចុះកាលបរិច្ឆេទពីសម័យកម្ពុជាប្រជាធិបតេយ្យ ឱ្យបញ្ជូនឯកសារដើមណាមួយនៃឯកសារទាំងនោះដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួនមកឱ្យ អ.វ.ត.ក។ ជាការបន្ថែម មេធាវីការពារក្ដីស្នើអង្គជំនុំជម្រះឱ្យ៖ បំពេញចិត្តរបស់ខ្លួនអំពីចំនួនឯកសារពិតប្រាកដ ដែលមាននៅក្នុងសំណុំរឿងដែលរក្សាទុកដោយ DC-Cam និងដែលគេគិតថាជាឯកសារដើម; និង បង្គាប់ឱ្យ DC-Cam ផ្ដល់សេចក្ដីពិស្ដារអំពីខ្សែសង្វាក់នៃការគ្រប់គ្រងចំពោះឯកសារសហកាលដើមនិមួយៗទាំងនេះ។ ប៉ុន្តែដោយគ្មានអំណះអំណាងខាងផ្លូវច្បាប់ ត្រូវបានបញ្ចេញឱ្យដឹងដោយមេធាវីការពារក្ដីនៅក្នុងតួសេចក្ដីនៃសំណើនេះ ដើម្បីគាំទ្រដល់ទម្រង់បន្ថែមចំនួនពីរ ចំពោះដំណោះស្រាយទាំងនេះ សហព្រះរាជអាជ្ញាពិចារណា ថាសហព្រះរាជអាជ្ញាមិនទទួលបានសំអាងគ្រប់គ្រាន់ទេ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមធ្វើការ ឆ្លើយតបរបស់ខ្លួនកម្រិតត្រឹមតែដំណោះស្រាយជាបឋមដែលបានស្វែងរកតែប៉ុណ្ណោះ។

2. សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះគួរបដិសេធចោលសំណើរបស់មេធាវីការពារក្ដីនេះ ដែលស្នើឱ្យបង្គាប់ទៅDC-Cam ឱ្យផលិតឯកសារដើមនៃឯកសារសហកាលសម័យកម្ពុជាប្រជាធិបតេយ្យទាំងអស់ដែលស្ថិតក្រោមការកាន់កាន់របស់ខ្លួនមកឱ្យ អ.វ.ត.ក។ ជាពិសេសយើងសន្និដ្ឋានថា (ក)

---

[1] **E168**, Requête aux Fins de Production à L'audience des Document D'époque en Original, ៦ កុម្ភៈ ២០១២ ("សំណើ")។ សំណើនេះ ត្រូវបានជូនដំណឹងជាភាសាបារាំង និងខ្មែរ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ធ្វើឱ្យថ្ងៃចុងក្រោយសម្រាប់ការដាក់ចម្លើយតប ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។

គេគ្មានលទ្ធខណ្ឌតម្រូវផ្នែកច្បាប់សម្រាប់ឯកសារដើមនៃឯកសារសហកាលទាំងអស់ ដែលកំពុងកាន់កាប់ដោយDC-Cam ត្រូវផលិតនៅពេលនេះទេ; (ខ) ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី ការពិតច្បាប់ដើមត្រូវបានពិគ្រោះយោបល់នៅក្នុងអម្លុងនៃដំណើរការស៊ើបសួរ ហើយច្បាប់ចម្លងនៃឯកសារទាំងនោះក៏ត្រូវបានដាក់ទៅក្នុងសំណុំរឿង និង (គ) គេនឹងមានការលំបាកផ្នែកភស្តុភារជាច្រើន នៅក្នុងការទុកដាក់ច្បាប់ដើមទាំងអស់នៅ អ.វ.ត.ក នៅទូទាំងសវនាការជំនុំជម្រះ។ យ៉ាងណាក៏ដោយ បើអង្គជំនុំជម្រះធ្វើការពិនិត្យមើលច្បាប់ដើមនានានៅក្នុងដំណាក់កាលនេះ សហព្រះរាជអាជ្ញាសូមស្នើថា សូមឲ្យគេផ្ញើរមក អវតក នូវគំរូយ៉ាងមួយចំនួនតូចនៃប្រភេទឯកសារផ្សេងៗគ្នានីមួយៗ ដែលបានរក្សាទុកនៅ DC-Cam តែប៉ុណ្ណោះបានហើយ គឺពុំចាំបាច់ធ្វើការផ្ញើរឯកសារទាំងស្រុងដែល DC-Cam បានប្រមូលនោះទេ។

## II. **ប្រវត្តិពាក់ព័ន្ធ**

3. អង្គជំនុំជម្រះបានលៃទុកពេលក្នុងសប្តាហ៍ពីថ្ងៃទី១៦ ដល់១៩ ខែមករា ឆ្នាំ២០១២[2] សម្រាប់ភាគីធ្វើការសន្និដ្ឋានទៅលើគោលការណ៍ទូទៅ ដែលគ្រប់គ្រងលើការទទួលយកភស្តុតាងជាឯកសារ ហើយគេរំពឹងថា ការធ្វើអំណះអំណាងជំទាស់ពាក់ព័ន្ធនឹងការទទួលយកឯកសារដែលបានលើកឡើងនៅក្នុងកំណត់សំគាល់ចុងទំព័រនៃកថាខណ្ឌនានានៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងសាវតាប្រវត្តិសាស្ត្រ[3] និងឯកសារចុះបញ្ជីក្នុងឧបសម្ព័ន្ធ ១ ដល់ ៥ នៃបញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងរបស់សហព្រះរាជអាជ្ញា[4]។

---

2 សូមអានឯកសារE159 អនុស្សរណៈដែលមានចំណងជើងថា "ការកំណត់ពេលសម្រាប់សវនាការផ្ទាល់មាត់អំពីឯកសារ", ១១ មករា ២០១២។

3 ឯកសារទាំងនេះត្រូវបានផ្តល់នូវការចាត់ថ្នាក់ជា E3 នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ និងត្រូវបានពិចារណាដោយអង្គជំនុំជម្រះថាបានដាក់នៅចំពោះមុខខ្លួន។ សូមអានឯកសារ **E1/16** កំណត់ហេតុជាលាយល័ក្ខអក្សរនៃកិច្ចដំណើរការនីតិវិធី នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ (ថ្ងៃទី៤) ទំព័រទី៤ និងឯកសារភ្ជាប់របស់វាលេខ **E1/16.2**។

4 **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឯកសារដែលពាក់ព័ន្ធនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះ, ២២ កក្កដា ២០១១ និងឯកសារភ្ជាប់របស់វាលេខ E109/4.1-4.20។

4. ក្នុងពេលសវនាការ មេធាវីការពារក្ដីនៅតែប្រកាន់ជំហររបស់ខ្លួនដដែល ដូចបានកំណត់នៅក្នុងការដាក់ឯកសារជាលាយល័ក្ខអក្សរនានាកាលពីលើកមុនៗថា ឯកសារច្បាប់ដើមដែលមាននៅក្នុងសំណុំរឿងគួរតែត្រូវបានផលិត[5]។ សហព្រះរាជអាជ្ញាសូមតវ៉ាថា ភាពស៊ីសង្វាក់គ្នានឹងករណីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គេគ្មានលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ត្រូវផលិតច្បាប់ដើមនៃឯកសារទាំងអស់ឡើយ[6]។ មេធាវីការពារក្ដីបានគាំទ្របន្ថែមទៅលើសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលសុំឱ្យកោះហៅនាយក DC-Cam ចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្ដល់សេចក្ដីលម្អិតទៅលើឯកសារនានាដែលខ្លួនបានប្រមូល[7]។

5. បន្ទាប់ពីសវនាការផ្ទាល់មាត់ អង្គជំនុំជម្រះបានកោះអញ្ជើញអនុប្រធាន DC-Cam, លោក វ៉ាន់ថាន់ ពៅដារ៉ា ដើម្បីផ្ដល់សក្ខីកម្មអំពីវិធីសាស្ត្រនៃការប្រមូល ចងក្រង និងរក្សាទុកឯកសាររបស់ DC-Cam[8]។ លោក ពៅដារ៉ា បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងបានផ្ដល់សក្ខីកម្មចាប់ពីថ្ងៃទី ២៣ ដល់ ២៥ ខែមករា ឆ្នាំ២០១២[9]។ តាមសំណើរបស់មេធាវីការពារក្ដីទាំងបីក្រុម អង្គជំនុំជម្រះបានកោះអញ្ជើញនាយក DC-Cam ជាបន្តទៀត គឺលោក ឆាំង យុ ដើម្បីមកផ្ដល់សក្ខីកម្មនៅចំពោះមុខខ្លួន[10]។ លោក ឆាំង យុ បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងបានផ្ដល់សក្ខីកម្មនៅថ្ងៃទី១, ២ និង៦ ខែកុម្ភៈ ឆ្នាំ២០១២[11]។

---

5 សូមអាន **E131/6** ការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបញ្ជីឯកសាររបស់ភាគីដទៃ សម្រាប់វគ្គទីមួយនៃការជំនុំជម្រះលើកដំបូង, ១៤ វិច្ឆិកា ២០១១, ត្រង់កថាខណ្ឌទី៤៦-៧។ ឯកសារ **E9/29** ។ បញ្ជីឯសារ, ១៩ មេសា ២០១១, ត្រង់កថាខណ្ឌ១៧-១៩។

6 **E1/27.1** ប្រតិចារិក ចុះថ្ងៃទី១៦ មករា ២០១២, ត្រង់ទំព័រ៧២។

7 *ដដែលដូចខាងលើ,* ត្រង់ទំព័រ ១២៨។

8 **E131/23** ដីកាកោះហៅសាក្សី, ១៣ មករា ២០១២។

9 សូមអាន **E1/31.1** ប្រតិចារិក ចុះថ្ងៃទី២៣ មករា ២០១២, **E1/32.1** ប្រតិចារិក ចុះថ្ងៃទី២៤ មករា ២០១២, **E1/33.1** ប្រតិចារិក ចុះថ្ងៃទី២៥ មករា ២០១២។

10 **E159/2** ដីកាកោះហៅសាក្សី, ២៦ មករា ២០១២។

11 សូមអាន **E1/37.1** ប្រតិចារិក ចុះថ្ងៃទី២ កុម្ភៈ ២០១២, **E1/38.1** ប្រតិចារិក ចុះថ្ងៃទី២ កុម្ភៈ ២០១២, **E1/39.1** ប្រតិចារិក ចុះថ្ងៃទី៦ កុម្ភៈ ២០១២។

6. នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានផ្តល់ការសម្រេចផ្ទាល់មាត់មួយលើបទដ្ឋានសម្រាប់ការទទួលយកភ័ស្តុតាង[12] និងក្រោយមកបានបញ្ជាក់អះអាងអំពីការសម្រេចនេះនៅក្នុងអនុស្សរណៈមួយចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ("ការសម្រេចអំពីភាពអាចទទួលបាន")[13]។ អង្គជំនុំជម្រះបានសម្រេចថាឯកសារច្បាប់ដើម និងព័ត៌មានពិស្តារអំពីយថាភូត ដើមកំណើត និងខ្សែសង្វាក់នៃការគ្រប់គ្រងមិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់គោលបំណងនៃការទទួលយកធ្វើជាភ័ស្តុតាងទេ,ដោយបានថ្លែងយ៉ាងដូច្នេះថា:

> "[*ឯកសារគឺទទួលយកបានបើសិនជាឯកសារទាំងនេះ] បានបំពេញនូវបទដ្ឋានសញ្ញាបង្ហាញមួយក្រឡេកមើលចំពោះភាពពាក់ព័ន្ធ ភាពជឿទុកចិត្តបាន និងយថាភូត។ ឧទាហរណ៍ ប្រសិនបើឯកសារមួយមើលទៅហាក់ដូចជាមិនក្លែងបន្លំ ឬមិនមែនមិនតំណាងឲ្យភាពដើម នោះអង្គជំនុំជម្រះត្រូវចាត់ទុកថាជាឯកសារដែលបានដាក់នៅចំពោះមុខខ្លួន*"[14] ។

7. ក៏ប៉ុន្តែ អង្គជំនុំជម្រះបានកត់សំគាល់ថា នៅពេលត្រូវធ្វើការវាយតម្លៃចំពោះភ័ស្តុតាង ឯកសារច្បាប់ដើម "គឺជាវិធីសាស្ត្រនៃការបង្ហាញភ័ស្តុតាងដែលគេពេញនិយម និងទទួលបានទម្ងន់ធ្ងន់ជាងឯកសារច្បាប់ចម្លង"[15]។ នៅក្នុងបរិបទនៃស្ថានភាពភ័ស្តុតាងជាឯកសារនៅក្នុងករណីរឿងនេះ សូមជូនសេចក្តីសន្និដ្ឋានថា ការសម្រេចនេះត្រូវកម្រិតនៅត្រឹមសំណៅថតចម្លងក្រៅពីសំណៅចម្លង ណាដែលទាក់ទងនឹងសំណោចម្លងនោះ៖ (ក) ច្បាប់ដើមនៅមាននៅឡើយ។ (ខ)ច្បាប់ដើមទាំងនោះកំពុងតែស្ថិតនៅទីកន្លែងមួយដែលគេស្គាល់។ (គ)មិនមានមូលហេតុសមស្របណាមួយដែលត្រូវបានស្នើឡើង

---

[12] E1/34.1 ប្រតិចារិក ចុះថ្ងៃទី២៦ មករា ២០១២, ត្រង់ទំព័រ៨៥-៨៨។

[13] **E162** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងចំណែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, ថ្ងៃទី៣១ មករា ២០១២ ("ការសម្រេចអំពីភាពអាចទទួលយកបាន")។

[14] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ២។

[15] *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ៤។

ដោយភាគីណាមួយដែលលើកឡើងដើម្បីតវ៉ាប្រឆាំងអំពីញ្ហាដែលថា ឯកសារច្បាប់ចម្លងទាំងនេះមិនមែនជាច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើមនោះឡើយទេ។ បើសិនជា មានគ្រប់តាមលក្ខណ្ឌទាំងបីនេះហើយនោះ សូមជូនសេចក្ដីសន្និដ្ឋានថា គួរតែបានផ្ដល់ចំពោះឯកសារច្បាប់ថតចម្លង ឬ ច្បាប់ចម្លងជាទម្រង់អេឡិចត្រូនិច ដូចគ្នានឹងទម្ងន់នៃឯកសារជាច្បាប់ដើមដែលជាឯកសារសរសេរ ឬបោះពុម្ពលើក្រដាស(ផ្នែករឹង)ដែរ។

## III. **អំណះអំណាង**

### ក. គ្មានលក្ខខណ្ឌតម្រូវផ្លូវច្បាប់សម្រាប់ការផលិតឯកសារច្បាប់ដើមទាំងអស់ចេញពី DC-Cam ទេនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី

8. សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានពីមុនរួចហើយ[16]ថា គេគ្មានលក្ខខណ្ឌតម្រូវដាច់ខាត ទាំងនៅ អ.វ.ត.ក នឹងទាំងនៅតាមបណ្ដាតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលត្រូវឲ្យផលិតឯកសារច្បាប់ដើមទេ។ អ្វីដែលគេហៅថា "វិធានស្ដីពីភ័ស្តុតាងល្អបំផុត" នោះ ត្រូវតែគេមើលឃើញទៅតាមបរិបទ និងកាលៈទេសៈនៃករណីនិមួយៗ។ ជាការសមស្របដែលត្រូវមានការគិតគួរចំពោះការពិចារណាពាក់ព័ន្ធនឹងការគ្រប់គ្រងសវនាការ រួមទាំងការពន្យារពេល ការលំបាកនៅក្នុងទម្លាប់នៃការអនុវត្ត និងការចំណាយផ្សេងៗ នៅពេលធ្វើការកំណត់សម្រេចអំពីភ័ស្តុតាងល្អបំផុត និងអំពីថាតើច្បាប់ដើមគឺពិតជាតម្រូវការចាំបាច់មែនឬទេ។

---

[16] សូមអាន **E114/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ការជំទាស់របស់ អៀង សារី ចំពោះប្រភេទខ្លះនៃឯកសារ"១៦ កញ្ញា ២០១១។ **E131/19** ចម្លើយតបរួមទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់វគ្គដំបូងនៃការជំនុំជម្រះរបស់សហព្រះរាជអាជ្ញា, ២ ធ្នូ ២០១១ ត្រង់កថាខណ្ឌ៥៥-៥៩។ E1/23.1 ប្រតិចារិក ចុះថ្ងៃទី១៥ ធ្នូ ២០១១, ត្រង់ទំព័រ៨៦។ E1/24.1 ប្រតិចារិក ចុះថ្ងៃទី១០ មករា ២០១២, ត្រង់ទំព័រ៥៣-៥៥។ E1/27.1 ប្រតិចារិក ចុះថ្ងៃទី១៦ មករា ២០១២, ត្រង់ទំព័រ១៧។ E1/27.1 ប្រតិចារិក ចុះថ្ងៃទី១៩ មករា ២០១២, ត្រង់ទំព័រ៥២-៥៣។

9. នៅក្នុងការសម្រេចស្ដីពីភាពអាចទទួលយកបានរបស់ខ្លួន ដូចបានយោងខាងលើ អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា បើជាបញ្ហាទូទៅ ច្បាប់ដើមមិនមែនជាលក្ខខណ្ឌតម្រូវទេនៅដំណាក់កាលនៃការទទួលយក ដរាបណាឯកសារនោះបានបំពេញនូវ បទដ្ឋាន *មួយក្រឡេកមើលដែលបញ្ជាក់បាន* អំពីភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន។ ការណ៍នេះគឺវាស៊ីគ្នានឹងការសម្រេចផ្ទាល់មាត់ដែលបានធ្វើឡើងម្ដងហើយម្ដងទៀតរបស់អង្គជំនុំជម្រះដែលថា ច្បាប់ដើមនៃឯកសារ មិនជាលក្ខខណ្ឌតម្រូវត្រូវបង្ហាញសាក្សីនៅទូទាំងដំណើរការនៃសក្ខីកម្មរបស់ពួកគាត់ឡើយ[17]។ ក្នុងការសម្រេចដូច្នេះ អង្គជំនុំជម្រះបានកត់សំគាល់ជាពិសេសអំពីការលំបាកផ្សេងៗដែលនឹងបង្កឡើងចំពោះការផលិតឯកសារដើមជូនសាក្សីដោយមានការយល់ឃើញអំពីចំនួនដ៏ច្រើននៃឯកសារនៅក្នុងសំណុំរឿង[18]។

10. តាមពិត វាអាចមានកាលៈទេសខ្លះដែលមានកំរិតថានឹងតម្រូវឲ្យមានការផលិតនូវឯកសារច្បាប់ដើមនៅមុន ពេលឯកសារនោះត្រូវបានទទួលយក។ ជាឧទាហរណ៍ ក្នុងការសម្រេចស្ដីពីភាពអាចទទួលយកបាន របស់ខ្លួន អង្គជំនុំជម្រះឲ្យដឹងថាឯកសារដែលហាក់ដូចជា "ក្លែងបន្លំ ឬមិនតំណាងឲ្យច្បាប់ដើម" អាច មិនត្រូវបានទទួលយក។ គេគ្មានកាលៈទេសដូច្នេះទេនៅក្នុងករណីពេលនេះ។ ទាក់ទងនឹងចំណុចនេះ ការពឹងផ្អែករបស់មេធាវីការពារក្ដីទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ នេះនៅក្នុងករណីរឿងក្ដី ឌុច[19] និងសេចក្ដីសម្រេចមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY) ក្នុងរឿងក្ដី *Bagosora*[20] ដែលតម្រូវឲ្យផលិតនូវច្បាប់នោះ គឺជាការយល់ច្រឡំ។

---

17 **E1/23.1** ប្រតិចារិក ចុះថ្ងៃទី១៥ ធ្នូ ២០១១, ត្រង់ទំព័រ៨៦។ **E1/24.1** ប្រតិចារិក ចុះថ្ងៃទី១១ មករា ២០១២, ត្រង់ទំព័រ៩-១០, ៥១។ **E1/25.1** ប្រតិចារិក ចុះថ្ងៃទី១១ មករា ២០១២, ត្រង់ទំព័រ៨, ៤១។

18 **E1/23.1** ប្រតិចារិក ចុះថ្ងៃទី១៥ ធ្នូ ២០១១, ត្រង់ទំព័រ៨៦។ **E1/24.1** ប្រតិចារិក ចុះថ្ងៃទី១០ មករា ២០១២, ត្រង់ទំព័រ៩-១០, ៥១។

19 **D288/6.5/10/2** សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃសម្ភារៈថ្មីៗ និងការបង្គាប់ដល់ភាគី, ១០ មីនា ២០០៩។

20 *រដ្ឋអាជ្ញា ទល់នឹង Bagosora*, ICTR-98-41-T, សេចក្ដីសម្រេចលើញត្តិស្នើសុំរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកសម្ភារៈជាក់លាក់មួយចំនួន ស្របតាមវិធាន៨៩(គ), ១៤ តុលា ២០០៤។

11. ទាំងនៅក្នុងរឿងក្តី *ឌុច* និងទាំងនៅក្នុងរឿងក្តី *Bagosora,* ឯកសារដែលរងការជំទាស់តវ៉ា គឺជាឯកសារសរសេរដោយដៃមួយច្បាប់ដែលគេបានអះអាងថា ជនជាប់ចោទជាអ្នកសរសេរ ហើយជនជាប់ចោទបានលើកឡើងពីកង្វល់យ៉ាងធ្ងន់ធ្ងរចំពោះយថាភូតរបស់ឯកសារនេះ។ ចំណែកក្នុងករណី *ឌុច* វិញ គឺជនជាប់ចោទបានបដិសេធថា គាត់មិនបានសរសេរឯកសារនោះទេ និងថា មិនដែលមានឯកសារដូច្នេះទេ។ អ្វីដែលផ្ទុយស្រឡះពីនេះ គឺមេធាវីការពារក្តីស្វែងរកឱ្យមានការផលិតនូវឯកសារច្បាប់ដើម *ទាំងអស់* ក្នុងខណៈដែលមេធាវីការពារក្តីខកខានម្តងហើយម្តងទៀតមិនបានលើកឡើងអំពីការតវ៉ាជាក់លាក់ណាមួយ ចំពោះយថាភូតនៃឯកសារជាក់លាក់ណាមួយទាល់តែសោះ សូម្បីតែនៅពេលផ្តល់ឱកាសដ៏បរិបូណ៌ទាំងក្នុងការដាក់ឯកសារជាលាយល័ក្ខអក្សរ និងទាំងក្នុងពេលសវនាការផ្ទាល់មាត់ក្តី។ និយាយឱ្យសាមញ្ញ គឺមេធាវីការពារក្តីបានខកខានមិនបានពាំនាំភាពមន្ទិលសង្ស័យឱ្យបានគ្រប់គ្រាន់ចំពោះឯកសារពាក់ព័ន្ធណាមួយ ធ្វើជាយុត្តិកម្មដើម្បីឱ្យមានការផលិតនូវឯកសារច្បាប់ដើមផ្នែករឹងសម្រាប់ការដេញដោលឡើយ។

12. មានការអនុវត្តតាមដែលថា គេគ្មានលក្ខខណ្ឌតម្រូវដើម្បីឱ្យមានការផលិតនូវច្បាប់ដើមផ្នែករឹងពី DC-Cam ទៅនៅដំណាក់កាលនេះ។ បើសិនជាអង្គជំនុំជម្រះពិចារណានៅពេលវាយតម្លៃលើភ័ស្តុតាងថា វាជាការចាំបាច់ដើម្បីពិនិត្យឯកសារច្បាប់ដើមផ្នែករឹង ដើម្បីបំពេញចិត្តខ្លួនដែលថាច្បាប់អេឡិចត្រូនិចនៅលើសំណុំរឿងគឺជាច្បាប់ចម្លងពិតប្រាកដ និងអាចផ្តល់ទម្ងន់ពេញលេញនោះការរៀបចំសមស្របមួយគួរតែបានធ្វើឡើងនៅពេលនោះ។

### ខ. ច្បាប់ដើមត្រូវបានប្រឹក្សាយោបល់នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ហើយច្បាប់ចម្លងនៃឯកសារទាំងនោះ ក៏បានដាក់នៅក្នុងសំណុំរឿង

13. មេធាវីការពារក្ដីអះអាងថា ច្បាប់ដើមនៃឯកសារដែលមាននៅក្នុងសំណុំរឿង មិនដែលត្រូវបានពិនិត្យដោយ សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ហើយលោក ឆាំង យុ ក៏បានបញ្ជាក់យ៉ាងច្រើន ហើយតាមរយៈសក្ខីកម្មផ្ទាល់មាត់របស់គាត់[21]។ នេះគឺការអះអាងមិនត្រឹមត្រូវ និងមិនតំណាងឲ្យសក្ខីកម្មរបស់លោក ឆាំង យុ ទេ។ នៅក្នុងការធ្វើអំណះអំណាងនេះ មេធាវីការពារក្ដីហាក់ដូចជាពឹងផ្អែកតែទៅលើចម្លើយមួយគត់របស់លោក ឆាំង យុ នៅក្រោមការសួរដេញដោលសាក្សី, សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមិនបានស្នើឲ្យ "ផ្ទៀងផ្ទាត់ជាមួយច្បាប់ដើម"។ ប៉ុន្តែនៅពេលផ្នែកដែលពាក់ព័ន្ធនៃសក្ខីកម្មរបស់លោក ឆាំង យុ ត្រូវបានសួរដេញដោល ពេញលេញ និងដោយគិតគូរជាមួយចម្លើយផ្សេងទៀត ដែលគាត់បានធ្វើនៅលើបញ្ហានេះក្នុងអម្លុងពេលនៃការផ្ដល់សក្ខីកម្មរបស់គាត់ ជាមួយនឹងភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង គឺច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតពិតជាបានពិគ្រោះយោបល់ អំពីច្បាប់ដើមនៃឯកសារ ហើយបានទទួលយក ឯកសារស្កេនពីច្បាប់ដើមទាំងនោះពីមជ្ឈមណ្ឌល DC-Cam។ ផ្នែកដែលពាក់ព័ន្ធនៃសក្ខីកម្មនេះ មានដូចខាងក្រោម៖

> *មកទល់សព្វថ្ងៃនេះ - សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតពុំដែល ស្នើសុំមើលឯកសារផ្ទៀងផ្ទាត់ទេ ប៉ុន្តែ<u>បានធ្វើការស្កេនដោយខ្លួនឯង ចេញពីឯកសារដើម</u> ដូចជា លោក Heder មកពី កសចស បានធ្វើដូច្នេះ[22] ។*

14. ចំណុចនេះត្រូវបានបញ្ជាក់ដោយលោក ឆាំង យុ ក្នុងពេលផ្សេង ក្នុងពេលផ្ដល់សក្ខីកម្មរបស់គាត់។ គាត់បាននិយាយថា៖

> *កសចស បានស្នើសុំធ្វើការស្កេនឯកសារចេញពីឯកសារដើម ដោយផ្ទាល់ខ្លួនឯងតែម្ដង[23] ។*

[21] **E168** សំណើ, កំណត់សំគាល់ខាងដើមលេខ ១ ត្រង់កថាខណ្ឌទី៣ (ដែលលើកយោងសេចក្ដីព្រាងប្រតិចារិក (ជាភាសាបារាំង), ២ កុម្ភៈ ២០១២ ត្រង់ទំព័រទី១៣, បន្ទាត់១៨-២០) និងកថាខណ្ឌ១៦។

[22] **E1/38.1** ប្រតិចារិក, ថ្ងៃទី២ កុម្ភៈ ២០១២ ត្រង់ទំព័រ១៣ (សង្កត់ន័យត្រង់ឃ្លាមានគូសបន្ទាត់ពីក្រោម)។

[23] *ដដែលដូចខាងលើ,* ត្រង់ទំព័រ១៥។

*[នៅ] ការិយាល័យសហចៅក្រមស៊ើបអង្កេត ពួកគាត់បានយកតួលេខកំណត់សំគាល់ខាងក្រោម នៃលេខឯកសារដើមទាំងនោះ ហើយពួកគាត់ក៏ស្នើសុំឯកសារច្បាប់ដើមទាំងនោះ មកស្កេនតែម្តង*[24] ។

15. ព័ត៌មាននៅក្នុងសំណុំរឿង និងភាពរកបាននៃព័ត៌មានទាំងនោះសម្រាប់គូភាគីនានា ក៏ត្រូវបានបញ្ជាក់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស) ទទួលបានជាទៀងទាត់នូវឯកសារស្កែនពីច្បាប់ដើមពណ៌ធម្មជាតិ ដែលឯកសារទាំងនោះស្ថិតក្រោមការកាន់កាប់របស់ DC-Cam, ហើយដែលក្នុងករណីភាគច្រើនក៏បានពិគ្រោះយោបល់ដោយផ្ទាល់អំពីច្បាប់ដើមនៅការិយាល័យ DC-Cam។ ជាឧទាហរណ៍ សហព្រះរាជអាជ្ញាសូមលើកយករបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ កសចស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨[25], ៦ កុម្ភៈ ២០០៩[26], ១៧ កុម្ភៈ ២០០៩[27], ២៦ សីហា ២០០៩[28], ២៧ សីហា ២០០៩[29] និង ៣១ សីហា ២០០៩[30] ទាក់ទងនឹងការទទួលឯកសារពី DC-Cam ដែលថ្លែងថាច្បាប់ដើមត្រូវបានពិគ្រោះ និង/ឬច្បាប់ចម្លងពណ៌ធម្មជាតិពីច្បាប់ដើម ត្រូវបានទទួល។ ការពិនិត្យមើលឯកសារដែលបានដាក់រួមគ្នាជាមួយនិងរបាយការណ៍ទាំងនេះ ពិតជាបានបង្ហាញថា ឯកសារទាំងនោះមានបញ្ចូលឯកសារពណ៌ធម្មជាតិដែលបានស្កែនចេញពីច្បាប់ដើមមែន។

16. ការលើកសំអាងរបស់មេធាវីការពារក្តីដែលថា ឯកសារច្បាប់ដើមទាំងឡាយចាំបាច់ត្រូវតែបង្ហាញជូនអង្គជំនុំជម្រះ ពីព្រោះច្បាប់ដើម មិនដែលបានឃើញ ឬស្នើសុំទេ ហេតុដូចនេះមិនអាចការពារបានឡើយ។

---

24 *ដដែលដូចខាងលើ,* ត្រង់ទំព័រ១៦។

25 **D43/IV** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។

26 **D175/5** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩។

27 **D175/6** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩។

28 **D248/5.3** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។

29 **D248/5.4** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

30 **D248/6.3** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

**គ. គឺមុខជានឹងមានការលំបាកយ៉ាងខ្លាំងនៅក្នុងការរក្សាទុកនូវរាល់ឯកសារច្បាប់ដើមទាំងអស់ នៅ អវតក នៅក្នុងទូទាំងអម្លុងពេលនៃសវនាការទាំងមូល**

17. មេធាវីការពារក្តីបានកត់សំគាល់ថា តាមចម្លើយរបស់លោក ឆាំង យុ, បានឆ្លើយថាត្រូវការរយៈពេលចំនួន តែមួយខែ ប៉ុណ្ណោះ ដើម្បីបញ្ជូនមកតុលាការ នូវឯកសារច្បាប់ដើមសម័យនោះ ដែល កាន់កាប់ថែរក្សាដោយ DC-Cam[31]។ ក៏ប៉ុន្តែ មេធាវីការពារក្តីមិនបានពិចារណាដល់ផលវិបាកផ្សេងៗទៀតដែលនឹងកើតឡើងនៅក្នុងការផ្ទេរបញ្ជូនកម្រងឯកសារច្បាប់ដើមកាលពីសម័យកម្ពុជាប្រជាធិបតេយ្យទាំងមូលរបស់ DC-Cam នោះឡើយ។

**ឃ. ជាជំរើមួយទៀត គួរបានធ្វើការផ្ទេរបញ្ជូនមកកាន់ អវតក តែគំរូមួយចំនួនដែលបានជ្រើសរើសពីក្នុងចំណោមឯកសារច្បាប់ដើមដែលរក្សាទុកដោយ DC-Cam បានហើយ**

18. ទីមួយ ការផ្ទេរបញ្ជូននូវកម្រងឯកសារនេះដែលមានចំនួនរាប់ពាន់ទំព័រ បើសិនជាវាមិនបានគ្របសង្កត់ឲ្យលិចបាត់ទេនោះ ក៏វាមុខជានឹងធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងហួសកំរិត ដល់សមត្ថភាពក្នុងការរក្សាទុកឲ្យបានប្រកបដោយសុវត្ថិភាពនៃផ្នែកឯកសារ និងបណ្ណសារ (RAU) ផងដែរ។ ទីពីរ ការកាន់ចុះកាន់ឡើងជាប្រក្រតីនូវឯកសារច្បាប់ដើមទាំងនេះដោយភាគី និងសាក្សីនានា នៅក្នុងទូទាំងអម្លុងពេលនៃសវនាការជំនុំជម្រះក្តីទាំងមូល ចាំបាច់គឺវាមុខជានឹងបណ្តាលឲ្យឯកសារច្បាប់ដើមទាំងនេះ ដែលមានអាយុរវាងពី៣៥ ទៅ៤០ឆ្នាំហើយ ដែលមានសភាពសភាពផុយស្រួយស្រាប់ទៅហើយនោះ[32] មានសភាពទ្រុឌទ្រោម។

---

[31] **E168** សំណើសុំ, កំណត់សំគាល់លេខ ១ ពីខាងដើម ត្រង់កខថាណ្ឌទី៩ (ដែលលើកសំអាងទៅលើពង្រាងនៃប្រតិចារិក (ជាភាសាបារាំងh), ចុះថ្ងៃទី២ កុម្ភៈ ២០១២ ត្រង់ទំព័រទី៣២ ពីបន្ទាត់ទី១៤-២៥)។

[32] លោក ឆាង យុ បានផ្តល់សក្ខីកម្មថា ឯកសារមួយចំនួនជាពិសេសបានរហែក ឬមានសភាពពុកផុយ។ សូមអានឯកសារលេខ **E1/37.1** ប្រតិចារិក ចុះថ្ងៃទី១ កុម្ភៈ ២០១២ ត្រង់កថាខណ្ឌទី១១៧-១១៨។

## ឃ. ជាជំរើសម៉្យាងទៀត គួរបានធ្វើការផ្ទេរបញ្ជូនមកកាន់ អវតក តែគំរូឯកសារមួយចំនួនដែលបាន ជ្រើសរើសពីក្នុងចំណោមឯកសារច្បាប់ដើមដែលរក្សាទុកដោយ DC-Cam វិញ

19. ដោយសារតែមានការផ្តល់ជូនភាពងាយរកបាននូវឯកសារច្បាប់ចម្លង ពីឯកសារច្បាប់ដើមនានា ដែលនៅក្នុងសំណុំរឿងតាមរយៈប្រព័ន្ធអេឡិចត្រូនិច និងដោយមិនមានការមន្ទិលសង្ស័យអំពីយថាភាពនៃច្បាប់ចម្លងនៃឯកសារទាំងនេះ សហព្រះរាជអាជ្ញា សូមស្នើថា ឯកសារច្បាប់ដើមផ្នែករឹងទាំងនេះ គួរបានស្ថិតនៅក្នុងទីកន្លែងរក្សាទុកប្រកបដោយសុវត្ថិភាពរបស់ DC-Cam ដដែល លុះត្រាតែ និងរហូតដល់ពេលដែលអង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវការពិនិត្យមើលនូវឯសារទាំងនេះនៅ ក្នុងពេលធ្វើការវាយតម្លៃលើភស្តុតាងនោះ ទើបស្នើឲ្យមានការផ្ទេរបញ្ជូនមក។

20. ក៏ប៉ុន្តែ បើសិនជា អង្គជំនុំជម្រះ បានគិតថាចាំបាច់ត្រូវធ្វើការពិនិត្យមើលលើឯកសារច្បាប់ដើមនៅក្នុងដំណាក់កាលនេះ, សហព្រះរាជអាជ្ញា សូមស្នើថា ប្រសើរជាជាងការផ្ទេរបញ្ជូននូវកម្រងឯកសាររបស់ DC-Cam ទាំងមូលមក គឺគ្រាន់តែបញ្ជូននូវឯកសារជ្រើសរើសសំរាប់ជាគំរូមួយចំនួនពីក្នុងចំណោមប្រភេទផ្សេងៗនៃឯកសារដែលបានរក្សាទុកដោយ **DC-Cam** គឺជាការគ្រប់គ្រាន់ហើយ ដែលក្នុងនោះរួមមាន ឯកសារប្រវត្តិរូប ឯកសារចម្លើយសារភាព ឯកសារបោះពុម្ពផ្សាយផ្សេងៗរបស់ បកក។ ការធ្វើដូច្នេះ នឹងជួយឲ្យ អង្គជំនុំជម្រះ អាចចាត់ទុកថា គឺវាមានលក្ខណៈគ្រប់គ្រាន់ហើយ ដើម្បីការបង្ហាញឲ្យឃើញថា ច្បាប់ចម្លងទាំងឡាយនៃឯកសារដែលនៅក្នុងទម្រង់ជាអេឡិចត្រូនិចនៅក្នុងសំណុំរឿង គឺជាតំណាងឲ្យឯកសារច្បាប់ដើមទាំងអស់។

## IV. ដំណោះស្រាយដែលបានស្នើសុំ

21. អាស្រ័យដោយមូលហេតុដូចដែលបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង ៖

១) បដិសេធចោលនូវសំណើនេះ។

២) ជាជំរើសម៉្យាងទៀត, បង្គាប់ឲ្យ Dc-Cam បង្ហាញជូន អវតក នូវគំរូនៃឯកសារដើម មួយចំនួនដែលត្រូវបានធ្វើការជ្រើសរើស៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] |